**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## លោកស្រី ផូ សុផាវី អនុប្រធាននាយកដ្ឋានរដ្ឋបាល និងសរុប និងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយរញ្ជួយចិត្តក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសិកា **សុខ សុំ** ដែលត្រូវជាម្តាយបង្កើត លោកស្រី **ផូ សុផាវី** អនុប្រធាននាយកដ្ឋានរដ្ឋបាល និងសរុបនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានទទួលមរណភាព នៅថ្ងៃពុធ ១៥រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៤:១៥ នាទីរសៀល ក្នុងជន្មាយុ ៩៥ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាអនេកប្បការជាមួយលោកស្រី និងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ ឧបាសិកា **សុខ សុំ** ដែលជាម្តាយ និងជីដូនជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបបួងសួងជូនវិញ្ញាណក្ខន្ធ ឧបាសិកា **សុខ សុំ** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកស្រី និងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ ព្រហស្បតិ៍ ១កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

ព្រុំ-សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh